# សម្ភាសន៍ជាមួយឈ្មោះ ឈិត សុខុម ភេទប្រុស អាយុ៦០ឆ្នាំ
## មុខងារសម័យខ្មែរក្រហមៈ «យោធា»
## ស្រុកកំណើតនៅភូមិត្រពាំងថ្នាន់ ឃុំលីបូរ ស្រុកត្រាំកក់ ខេត្តតាកែវ
## រស់នៅភូមិផ្អៀកជ្រុំ ឃុំផ្អៀកជ្រុំ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ
## ថ្ងៃទី២៦ ខែវិច្ឆកា ឆ្នាំ២០១៣
## សម្ភាសន៍ដោយៈ សុខ វណ្ណៈ
## ០០:៥០:២៨
## ១៩ទំព័រ

វណ្ណៈ៖ ចឹងពូជាដំបូងខ្ញុំចង់ណែនាំខ្លួនថា ខ្ញុំមកពីខាងណា?

សុខុមៈ ហ្នឹង ។

វណ្ណៈ៖ ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំឈ្មោះ សុខ វណ្ណៈ ហើយនេះឈ្មោះ ប៊ុន ថន ហើយមានពីរទៀតទៅជួបអ៊ំពីរនាក់ទៀតនោះមួយឈ្មោះ បូ លីនិងមួយទៀតឈ្មោះ ដានី គាត់ទៅសំភាសអ៊ំខាងនោះដែរ ហើយខ្ញុំបានមកដល់ភូមិឃុំពូគឺចង់ដឹងរឿងរ៉ាវប្រវត្តិដែលទាក់ទងពីសម័យសង្គ្រាម មកដល់បច្ចុប្បន្ន ហើយបទសំភាសរបស់ខ្ញុំដែលបានពីពូហ្នឹងយកទៅចងក្រងជាឯកសារជាសៀវភៅ ដើម្បីឲ្យក្មេងជំនាន់ក្រោយបានដឹងបានពូដែរ ចឹងពូមិនថាអីទេពូ?

សុខុមៈ បាទ ។

វណ្ណៈ៖ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះ ពូ ពូមានឈ្មោះអីដែរ?

សុខុមៈ ឈិត សុខុម ។

វណ្ណៈ៖ ពូអាយុប៉ុន្មានហើយ?

សុខុមៈ អាយុ៦០ ។

វណ្ណៈ៖ ចឹងពូមានអាយុហៅក្រៅទៀតទេ?

សុខុមៈ អត់ទេ ។

វណ្ណៈ៖ ប្រពន្ធពូឈ្មោះអីដែរ?

សុខុមៈ ឈ្មោះ ចាន់ រ៉ែម ។

វណ្ណៈ៖ គាត់មានអាយុប៉ុន្មានហើយ?

សុខុមៈ អាយុ៤០ជាង ។

វណ្ណៈ៖ ពូមានកូនចៅទាំងអស់ប៉ុន្មាននាក់ដែរ?

សុខុមៈ	មាន៨នាក់ ។

វណ្ណៈ	មានស្រីប៉ុន្មាន?

សុខុមៈ	ស្រី៥ ប្រុស៣ ។

វណ្ណៈ	ចឹងសព្វថ្ងៃពួធ្វើការអីដែរ?

សុខុមៈ	ធ្វើទាហាន ។

វណ្ណៈ	ធ្វើទាហាននៅក្នុងកងពលណា?

សុខុមៈ	កងពលលេខ៨ ។

វណ្ណៈ	កន្លែងហ្នឹងគេហៅតំបន់អីដែរ?

សុខុមៈ	គេហៅព្រះវិហារ ។

វណ្ណៈ	នៅជាមួយឧត្តមសេនីយ ស្រី ឌឹក?

សុខុមៈ	បាទ ។

វណ្ណៈ	ចឹងកូនលោកពូទាំង៨នាក់ហ្នឹងនៅក្នុងបន្ទុកគ្រួសារឬមួយបានរៀបការខ្លះហើយ?

សុខុមៈ	រៀបការអស់ហើយ នៅសល់ពីរ ។

វណ្ណៈ	ចឹងឪពុកពូឈ្មោះអីដែរ?

សុខុមៈ	ឈិត សំ ។

វណ្ណៈ	ម្ដាយ?

សុខុមៈ	យុត ម៉េន ម្ដាយ ។

វណ្ណៈ	ចឹងលោកទាំងពីរសព្វថ្ងៃគាត់នៅរស់ឬមួយស្លាប់អស់ហើយ?

សុខុមៈ	គាត់ស្លាប់ហើយតាំងពីរសម័យបីឆ្នាំ ។

វណ្ណៈ	ចឹងបងប្អូនបង្កើតពូមានប៉ុន្មាននាក់?

សុខុមៈ	មានបីនាក់ ។

វណ្ណៈ	ប្រុសប៉ុន្មានស្រីប៉ុន្មាន?

សុខុមៈ	មានប្រុស២ស្រី១ ។

វណ្ណៈ	បងទី១ឈ្មោះអីទៅ?

សុខុមៈ	ខ្ញុំ ។

វណ្ណៈ	ទី២?

សុខុមៈ	ឈិត សុខន ។

វណ្ណៈ	សព្វថ្ងៃគាត់នៅរស់ដែរ?

សុខុមៈ   ស្លាប់ហើយ ។

វណ្ណៈ   ទី៣ឈ្មោះអីដែរ?

សុខុមៈ   ឈិត ស្រីទូច ។

វណ្ណៈ   គាត់រាល់ថ្ងៃនៅណា?

សុខុមៈ   នៅភ្នំពេញ ។

វណ្ណៈ   ចឹងកាលពីនៅតូចពូបានរៀនសូត្រដល់ថ្នាក់ណាដែរ?

សុខុមៈ   ថ្នាក់ទី១០“ចាស់”កាលពីសង្គម ។

វណ្ណៈ   កាលហ្នឹងរៀននៅសាលាណាដែរ?

សុខុមៈ   នៅសាលាវត្តខត្តមសូរិយា កាលរៀនបានប៉ុន្មានកើតរដ្ឋប្រហារ ។

វណ្ណៈ   ចឹងស្រុកកំណើតពីតែម្តងនៅណាវិញ?

សុខុមៈ   នៅតាកែវ ។

វណ្ណៈ   នៅភូមិអីដែរ?

សុខុមៈ   ភូមិថ្វាន់ ឃុំលីបូ ស្រុកត្រាំកក់ ខេត្តតាកែវ នោះ ។

វណ្ណៈ   ចឹងពូឈប់រៀនដោយសារមានរឿងអីកើតឡើង?

សុខុមៈ   កាលជិនាន់ហ្នឹងកើតរដ្ឋប្រហារឆ្នាំ១៩៧០ កាលហ្នឹងគេជម្លៀសពីតំបន់ខាងក្រោមឲ្យទៅនៅខាងលើ ។

វណ្ណៈ   កាលឆ្នាំ១៩៧០ ពូឈប់រៀនគេជម្លៀសពូទៅខាងណាទៀត?

សុខុមៈ   នៅស្រុកត្រាំកក់ដែរ តែឡើងមកនៅលើថ្នល់ជាតិ ទៅនៅខាងមឿងចារ កាលហ្នឹងរៀនមិនបានបិតថេរ ។

វណ្ណៈ   ចឹងឆ្នាំណាបានពូបានចូលបម្រើបដិវត្តកាលហ្នឹង ចូលតាមការឃោសនាឬចូលតាមការប្រកាសរបស់សម្តេចសីហនុថាឲ្យកូនចៅចូលព្រៃម៉ាគីកាលហ្នឹង?

សុខុមៈ   ឆ្នាំ១៩៧២ តែគ្រាន់យើងធ្វើការនៅក្នុងស្រុកក្នុងភូមិនៅឡើយ ។

វណ្ណៈ   ចឹងឆ្នាំ១៩៧២ពូនៅភូមិតែម្តង?

សុខុមៈ   ចូលនៅក្នុងនៅខេត្តតាកែវនៅក្នុងស្រុក ។

វណ្ណៈ   នៅក្នុងឃុំលីបូដែរ?

សុខុមៈ   បាទ ។

វណ្ណៈ   នៅក្នុងតំបន់ប៉ុន្មាន?

សុខុមៈ   តំបន់១៣ ។

វណ្ណៈ  ចឹងកាលចូលដំបូងធ្វើជាយោធាតែម្តងឬគ្រាន់តែដើរឃោសនាទេ?

សុខុមៈ  ធ្វើជាយោធា ។

វណ្ណៈ  កាលហ្នឹងមានកងពលនៅ?

សុខុមៈ  នៅទេ មិនទាន់មានទេ ។

វណ្ណៈ  ចឹងកាលហ្នឹងគេរៀបចំយ៉ាងម៉េចទៅ?

សុខុមៈ  កាលហ្នឹងធ្វើជាឈ្លបធ្វើជាទ័ពស្រុកអីចឹងណាស់ កាលហ្នឹងវាមានតែឈ្លបនិងទ័ពស្រុកទ័ពតំបន់អីចឹង ។

វណ្ណៈ  ចឹងកាលហ្នឹងឆ្នាំណាបានពូឡើងទៅទ័ពស្រុក?

សុខុមៈ  អត់ទេ កាលហ្នឹងឡើងមកទ័ពភូមិភាគតែម្តង ។

វណ្ណៈ  ចឹងឡើងមកទ័ពភូមិភាគពូមានចាំឆ្នាំទេ?

សុខុមៈ  ឆ្នាំ១៩៧៤ ។

វណ្ណៈ  ចឹងកាលហ្នឹងនៅភូមិភាគហ្នឹងពីណាប្រធានធំប្រធានកងពលឬប្រធានភូមិភាគអីហ្នឹង?

សុខុមៈ  ប្រធានកងពលមានតាម៉ែត ដែលស្លាប់នៅលិចនោះ តាម៉ែត នៅលិចរាល់ថ្ងៃដឹងថាស្លាប់ឬនៅ ។

វណ្ណៈ  ចឹងប្រធានភូមិភាគពីណាគេ?

សុខុមៈ  មិនដឹងជាពីណាទេ ។

វណ្ណៈ  មិនមែនតាម៉ុកទេ?

សុខុមៈ  ម៉ាតំបន់ហ្នឹងឃើញតែគាត់ដើរជាមួយ ហ៊ូ នឹម ហ៊ូ យន់ ហ្នឹងតែមិនដឹងជាពីណាប្រធាន ។

វណ្ណៈ  ចឹងតាម៉ុកដែរ?

សុខុមៈ  ហ្នឹងហើយដើរជាមួយគាត់បីនាក់ហ្នឹង ។

វណ្ណៈ  ចឹងនៅឆ្នាំ១៩៧៤ហ្នឹងគេមានឲ្យឋានៈពូជាប្រធានក្រុម ប្រធានវរសេនាតូច វរសេនាធំអីទេកាលហ្នឹង?

សុខុមៈ  អត់មានទេ ។

វណ្ណៈ  ចឹងសង្គ្រាមកាលហ្នឹងវាយជាមួយខាងណាដែលពូ?

សុខុមៈ  វាយជាមួយខាង លន់ នល់ ហ្នឹង ។

វណ្ណៈ  ចឹងកាលហ្នឹងខាងខ្មែរក្រហមមានល្បឿនលឿនដោយសារមូលហេតុអីដែរ?

សុខុមៈ  កាលហ្នឹងមានស្ទីមានតែកម្លាំងចិត្ត  មានឆាន់ទាក់ប្រយុទ្ធតែម្តង  តែខ្ញុំកាលនោះមិនសូវបាន ប្រយុទ្ធអីទេខ្ញុំនៅតែកន្លែងមន្ទីរ  និយាយរួមការងារខ្ញុំមិនសូវយល់ព្រោះខ្ញុំនៅតែកន្លែងមន្ទីរ ស្រួលដែរ ។

វណ្ណៈ  គេហៅមន្ទីរអីគេ?

សុខុមៈ  មន្ទីរកងពល ។

វណ្ណៈ  កាលកងពលលេខប៉ុន្មាន?

សុខុមៈ  កាលហ្នឹងកងពលលេខ១ ។

វណ្ណៈ  កងពលទី១ឈ្មោះ តាម៉ត ដឹកនាំ?

សុខុមៈ  ហ្នឹងហើយ ។

វណ្ណៈ  ចឹងមួយកងពលហ្នឹងមានប៉ុន្មានវរសេនាធំពូ?

សុខុមៈ  មានបី ។

វណ្ណៈ  ចឹងមួយវរសេនាធំមានបីវរសេនាតូចបន្ទាប់ៗចឹង?

សុខុមៈ  បាទ ។

វណ្ណៈ  ចឹងកាលឆ្នាំ១៩៧៤ហ្នឹងរហូតដល់ដាច់ទីក្រុងភ្នំពេញហ្នឹង  តើមុនបានចូលដល់ទីក្រុងភ្នំពេញ ហ្នឹង យើងត្រូវការវាយយ៉ាងម៉េចខ្លះដែរ?

សុខុមៈ  កាលហ្នឹងនៅក្រោយខ្ញុំមិនសូវបានដឹងទេ ដូចខ្ញុំថាចឹងខ្ញុំនៅតែមន្ទីរខាងក្រោយ ។

វណ្ណៈ  ចឹងពេលដាច់ភ្នំពេញហើយ?

សុខុមៈ  ពេលដាច់ភ្នំពេញបានចូលមកដល់ត្រឹមតប៉ក្រញ៉  តែមិនបានប៉ុន្មានដងក្រោយមកបានដាកន្ទះ ខែហ្នឹង ។

វណ្ណៈ  ចឹងពូមានចូលដល់ភ្នំពេញទេ?

សុខុមៈ  ចូលបានត្រឹមពោធិចិនតុង ដល់ក្រោយមកខ្ញុំត្រឡប់ទៅខេត្តតាកែវវិញ ។

វណ្ណៈ  ចឹងឆ្នាំ១៩៧៥ពូត្រឡប់ទៅតាកែវវិញ?

សុខុមៈ  បាទ!ត្រឡប់ទៅតាកែវ នៅម្តុំថ្នល់បែកគូស ។

វណ្ណៈ  ចឹងកាលនៅឆ្នាំ១៩៧៥ឬ៧៦?

សុខុមៈ  ឆ្នាំ១៩៧៥ចប់ហើយ  អង្គភាពហ្នឹងទៅធ្វើផ្លូវនៅខេត្តតាកែវ  កងពលទី១ទៅធ្វើផ្លូវពីនេះទៅ តាកែវហ្នឹង ។

វណ្ណៈ  ចឹងបាននៅពោធិចិនតុងបានរយៈពេលប៉ុន្មាន?

សុខុមៈ  នៅបានតែមួយយប់ទេ ។

វណ្ណៈ: ចេញទៅតាកែវវិញហ្នឹងនៅម្តុំណាហើយធ្វើអីទៅ?

សុខុមៈ ធ្វើផ្លូវតែខ្ញុំអត់មានធ្វើអីទេ ខ្ញុំនៅតែកន្លែងទេ ខ្ញុំមិនដែលទៅណាផង ។

វណ្ណៈ: ចឹងជាយោធាជួសជុលផ្លូវ?

សុខុមៈ ចឹងកាលហ្នឹងកងទ័ពទាំងអស់ឲ្យធ្វើផ្លូវហ្នឹង ធ្វើបានប៉ុន្មានដកមកវិញ ។

វណ្ណៈ: ធ្វើផ្លូវពីណាទៅណា?

សុខុមៈ ផ្លូវជាតិលេខ៣អីហ្នឹង តែធ្វើមិនបានប៉ុន្មានគេដកមកវិញ ។

វណ្ណៈ: ផ្លូវជាតិលេខ៣ហ្នឹងយើងធ្វើពីតាកែវនៅកំពតឬពីតាកែវទៅភ្នំពេញ?

សុខុមៈ ហ្នឹងហើយធ្វើទៅកំពត និយាយរួមធ្វើនៅម្តុំអង្គតាសោមហ្នឹង មិនទាន់បានធ្វើអីណាច្រើន ។

វណ្ណៈ: ចឹងដល់ឆ្នាំ១៩៧៦-៧៧-៧៨អីហ្នឹង?

សុខុមៈ អាហ្នឹងមកនៅកំបូលវិញ ។

វណ្ណៈ: កំបូលខាងខេត្តណា?

សុខុមៈ ខាងលិចភ្នំពេញ ខាងអង្គស្នួល កំបូលបែកចានយើងនេះ ។

វណ្ណៈ: ចឹងឆ្នាំណាពូបានមកនៅហ្នឹង?

សុខុមៈ ឆ្នាំ១៩៧៦ហើយ ។

វណ្ណៈ: ចឹងមកកំបូលហ្នឹងគេឲ្យធ្វើអីដែរ?

សុខុមៈ ខ្ញុំអត់មានធ្វើអីទេ គេឲ្យនៅតែកន្លែងតែម្តង ។

វណ្ណៈ: ចឹងនៅមន្ទីរដែរ?

សុខុមៈ ហ្នឹងហើយ ។

វណ្ណៈ: គេហៅមន្ទីរអី?

សុខុមៈ គេហៅមន្ទីរកងពលដែលហ្នឹង ។

វណ្ណៈ: ចឹងនៅមន្ទីរកងពលហ្នឹងគេមានបទបញ្ជាធ្វើលិខិតស្នាមអីដែរ?

សុខុមៈ អត់ទេ នៅធម្មតា កងពលគេមាននេះគេហើយ តែខ្ញុំនៅធម្មតាអីមានធ្វើអីទេ ។

វណ្ណៈ: ចឹងនៅហ្នឹងប្រធានពីណាគេ?

សុខុមៈ ប្រធានមន្ទីរឈ្មោះ បង សំណាង តែគាត់ស្លាប់បាត់ហើយ ។

វណ្ណៈ: គាត់ស្លាប់ដោយសារមូលហេតុអី?

សុខុមៈ ធ្វើសង្គ្រាមឆ្នាំ១៩៧៩ហ្នឹង ។

វណ្ណៈ: ចឹងប្រធានកងពល?

សុខុមៈ ប្រធានកងពលហ្នឹងក៏ស្លាប់ដែរ ។

វណ្ណៈ: ពីណាគេ?

សុខុម: តាសឿន នោះ ស្លាប់ស្រករគ្នាហ្នឹងឯង តាសឿននិងបង សំណាង ។

វណ្ណៈ: ចឹងមកនៅកំបូលហ្នឹងគេហៅកងពលលេខប៉ុន្មានទៅ?

សុខុម: កងពលលេខ១ដដែល ពីដើមកងពល១៣ ក្រោយមកគេដូរកាលសម័យសង្គ្រាមក្រោយមកបានមកលេខ១ហ្នឹង ។

វណ្ណៈ: ចឹងពូនៅហ្នឹងដល់ឆ្នាំ១៩៧៩ឬមានការផ្លាស់ប្តូរទៀត?

សុខុម: អត់ទេ មកនៅលង្វែក ។

វណ្ណៈ: ឆ្នាំណាមកនៅលង្វែក?

សុខុម: ចុងឆ្នាំ១៩៧៦-៧៧ហ្នឹងហើយ ។

វណ្ណៈ: ចឹងពេលមកនៅលង្វែកពូនៅមន្ទីរដដែលហើយមានយោធាប្រហែលជាប៉ុន្មាននាក់ទៅ?

សុខុម: មកមួយកងពល ។

វណ្ណៈ: ចឹងមួយកងពលហ្នឹងមានប្រហែលជាប៉ុន្មាននាក់?

សុខុម: កាលហ្នឹងក្តាប់មិនបានទេ ។

វណ្ណៈ: ចឹងតាសឿនប្រធានកងពលដដែលឬមានការផ្លាស់ប្តូរដែរ?

សុខុម: តាសឿនដដែល ។

វណ្ណៈ: ចឹងនៅក្នុងឆ្នាំ១៩៧៧ហ្នឹង នៅលង្វែកហ្នឹងមានដូចថា មានការផ្លាស់ប្តូរមនុស្សឬក៏មានចាប់មនុស្សអីដែលទេ?

សុខុម: អត់មានចាប់ទេ ។

វណ្ណៈ: ចឹងនៅលង្វែកហ្នឹងការហូបចុកយ៉ាងម៉េចដែរ?

សុខុម: មានពេលខ្លះមានបាយមានបបរចឹងទៅ ជួនបបរព្រឹក បាយល្ងាចចឹងទៅ ។

វណ្ណៈ: ចឹងពេលនៅហ្នឹងពូមានតួនាទីអីទេ?

សុខុម: អត់ទេ ។

វណ្ណៈ: ចឹងពូនៅហ្នឹងរហូតដល់ឆ្នាំ១៩៧៩តែម្តងឬមានការផ្លាស់ប្តូរទៀត?

សុខុម: អត់ទេ មកខាងព្រះវិហារនេះបានប៉ុន្មានទេ មកនៅព្រះវិហារហ្នឹង ។

វណ្ណៈ: ឆ្នាំណាពូ?

សុខុម: ឆ្នាំ១៩៧៨-៧៩ហ្នឹង ។

វណ្ណៈ: កាលមកព្រះវិហារហ្នឹងមកគ្នាច្រើនឬមួយមកតែពូទេ?

សុខុម: កាលហ្នឹងមកច្រើនខ្លះគេនៅខាងខេត្តសៀមរាប ខ្លះមកខាងព្រះវិហារ ។

វណ្ណៈ ចឹងមកដល់ព្រះវិហារហ្នឹងគេឲ្យពូធ្វើអីដែរ?

សុខុមៈ ធ្វើកងទ័ព ។

វណ្ណៈ កាលហ្នឹងតំបន់ប៉ុន្មាន?

សុខុមៈ តំបន់១០៣ ។

វណ្ណៈ ចឹងពេលមកដល់ហ្នឹងយើងធ្វើការងារអីខ្លះទៅ មកដល់ព្រះវិហារហ្នឹង?

សុខុមៈ មានស្អីមកដល់នៅខាងកងទ័ព ។

វណ្ណៈ ចឹងកាលហ្នឹងឃើញមានប្រជាជនច្រើនទេ?

សុខុមៈ ប្រជាជននៅធម្មតាតាមហ្នឹង ។

វណ្ណៈ ចឹងកាលហ្នឹងពូនៅជាមួយពូ មាស វឿន ហ្នឹង ខាងកងពល?

សុខុមៈ អត់ទេ ។

វណ្ណៈ ពូមានស្គាល់ឈ្មោះ វឿន ទេ?

សុខុមៈ ស្គាល់ វឿន គណៈតំបន់ស្គាល់ ស្រមូម វឿន នោះគេហៅស្អី វឿន ទេ វឿន ស្រមូម គាត់ធ្វើគណៈតំបន់ ។

វណ្ណៈ ចឹងមកខេត្តព្រះវិហារហ្នឹងពីណាជាគណៈតំបន់?

សុខុមៈ ឈ្មោះ វឿន ហ្នឹង ។

វណ្ណៈ ចឹងឈ្មោះ វឿន គណៈតំបន់១០៣ហ្នឹងត្រកូលគាត់ស្អីវិញ?

សុខុមៈ កាលហ្នឹងខ្ញុំមិនសូវយកចិត្តទុកដាក់ ។

វណ្ណៈ ចឹងពេលពូមកដល់នេះការហូបចុកយ៉ាងម៉េចដែរ?

សុខុមៈ អត់មានអីទេ ។

វណ្ណៈ ចឹងមកដល់នេះមានការចាប់មនុស្សអីមានដឹងទេ?

សុខុមៈ ខ្ញុំមកដល់ហ្នឹងពេលមុនហ្នឹងគេមាន ខ្ញុំមកឃើញមានខ្លះនៅហ្នឹង ដល់ហើយគេដោះលែងអស់ទៅ មួយសារពួកខ្ញុំមកហ្នឹងអត់មានទេ ។

វណ្ណៈ ចឹងពូមករយៈពេលខ្លីដែរឆ្នាំ១៩៧៨-៧៩យួនជិតចូលស្រុកហើយ?

សុខុមៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងមានបានដើរមើលភូមិសាស្រ្តអីបានច្រើនទេ?

សុខុមៈ អត់ទេ កាលហ្នឹងនិយាយគេថាមានចោរព្រៃកើតឡើងនៅលើភ្នំនោះ ចុះទាហានចេះឯងទៅ ដេកតែលើខ្នងភ្នំនោះ ខ្នងភ្នំត្បែងមិនសូវគ្នាប់បានស្អីទេ រយៈពេលខ្លីពេលក្រោយមកយួនចូលស្រុកពួយតាមហ្នឹងរហូតទៅ ។

វណ្ណៈ៖ ចឹងពេលដែលយួនចូលស្រុកហ្នឹងពូមានបំណងនៅស្រុកកំណើតវិញឬមួយយ៉ាងម៉េច?

សុខុមៈ បំណងចេះតែមានតែយើងចេះតែគិតហើយ ព្រោះយើងនៅខាងនេះហើយចូលទៅចេះខ្លាចចេះក្រែងចឹងទៅណាស់ ដល់ចឹងយើងចេះទៅតាមអត្តភាពតាមព្រំដែនចឹងទៅ ។

វណ្ណៈ៖ ចឹងពេលចេញពីព្រះវិហារនៅខាងណាវិញ?

សុខុមៈ ទៅរហូតទៅទល់ចម្ការចេកចម្ការដូង ។

វណ្ណៈ៖ ចម្ការចេកចម្ការដូងនៅខាងណាវិញ?

សុខុមៈ នៅខាងភូមិភាគពាយ័ព្យ ។

វណ្ណៈ៖ ពាយ័ព្យខាងបាត់ដំបង?

សុខុមៈ ហ្នឹងហើយ ។

វណ្ណៈ៖ ចឹងពូទៅដល់សំឡូតអីដែរ?

សុខុមៈ អត់ទេ ។

វណ្ណៈ៖ ចឹងភូមិដូងនៅខាងម៉ាឡៃហ្នឹង?

សុខុមៈ ហ្នឹងហើយ ។

វណ្ណៈ៖ ចឹងកាលហ្នឹងនៅជាមួយ តាចៀម?

សុខុមៈ កាលហ្នឹងនៅជាមួយ តាវឿន ដែលហ្នឹងខាងកើតគ្រប់គ្រងមាន តាហុង អីហ្នឹងខាងផ្តល់ស្បៀងខាងនយោបាយអប់រំអី តែពួកខ្ញុំនៅជាប់ជាមួយ តាវឿន ហ្នឹងដដែល ។

វណ្ណៈ៖ ចឹងកាលហ្នឹងទៅខាងចូលក្រោយឆ្នាំ១៩៧៩ហ្នឹងទៅខាងហ្នឹង គេបង្កើតទ័ពដើម្បីវាយជាមួយទាហានរដ្ឋាភិបាលវិញ ចឹងខាងម៉ាឡៃហ្នឹងកងពលលេខប៉ុន្មានទៅ?

សុខុមៈ ពួកខ្ញុំអត់ទេ ពេលហ្នឹងដាច់ឈប់ កាលហ្នឹងមកជាប់ជាមួយគណៈតំបន់លែងមានសកម្មភាពអីហើយ ពួកកងទ័ពដាច់ដោយឡែកអស់ហើយ ។

វណ្ណៈ៖ ចឹងកាលពូនៅម៉ាឡៃពូនៅជាមួយប្រជាជន?

សុខុមៈ ខ្ញុំនៅជាមួយគណៈតំបន់ កម្លាំងប្អូនដប់នាក់ជាប់ជាមួយគាត់ហ្នឹងទៅ ។

វណ្ណៈ៖ គណៈតំបន់?

សុខុមៈ តាវឿន ហ្នឹង ។

វណ្ណៈ៖ ចឹងជាមួយតាវឿន ពូជានិរសាគាត់ឬមួយយ៉ាងម៉េច?

សុខុមៈ អត់ទេ គ្រាន់តែកម្លាំងកងទ័ពបំបែកអស់ពីព្រះវិហារនេះទៅ ចេះតែនៅផ្ញើរជុំវិញគណៈតំបន់ហ្នឹងទៅ អត់មានសកម្មភាពធ្វើអីអត់ទេ ។

វណ្ណៈ៖ ចឹងគាត់នៅរស់ដែលរាល់ថ្ងៃ?

សុខុមៈ ទេ មិនដឹងជាយ៉ាងម៉េច បែកគ្នាតាំងជំនាន់អូរគ្រាវអីនោះ ។

វណ្ណៈ ចឹងកាលពូនៅជាមួយតាវឿន ពូអត់មានឋានៈអីទេ?

សុខុមៈ អត់ទេ ។

វណ្ណៈ នៅជាយោធាដែលប៉ុមួយយ៉ាងម៉េច?

សុខុមៈ យោធា ។

វណ្ណៈ ចឹងយោធាកាលហ្នឹងមិនដឹងជាកងពលលេខប៉ុន្មានទេ ជាមួយតាហុងអីហ្នឹង?

សុខុមៈ ខ្ញុំអត់ទេ អត់មានពាក់ព័ន្ធជាមួយពួកហ្នឹងទេ ព្រោះកាលហ្នឹងតាវឿន គាត់មកកណៈតំបន់ដាច់កងពលកាលហ្នឹងដើរទៅជាមួយគេពួកកងពលគេមកពីខាងកើត ដល់ចឹងចេះតែទៅជាមួយគេចឹងទៅ ហើយពួកខ្ញុំអស់សាច់ដុំហើយកាលហ្នឹង ចុះកងទ័ពតំបន់មានអី គួនាទីតូចតាចខ្ចិលកាន់ក្រុមអីហ្នឹងគេដែរ ។

វណ្ណៈ តែក្រោយ៧៩អី គេរំសាយហើយកណៈតំបន់លែងមានហើយប៉ុយ៉ាងម៉េច?

សុខុមៈ អត់ទេ លែងមានហើយ ។

វណ្ណៈ ចឹងអ្នកណាដែលមានតួនាទីក្នុងសម័យបីឆ្នាំហ្នឹងគេអាចឲ្យធ្វើជាប្រធានកងពលវិញ ជាប្រធានវរសេនាធំវរសេនាតូចអី?

សុខុមៈ តាវឿនហ្នឹងក៏អត់ដែរ នៅពេលគេហៅទៅធ្វើការទៅ តាហុង អីគាត់ហៅទៅធ្វើការចឹងទៅមកវិញ មានអីមានតែណែនាំគ្រួសារកងទ័ព ណែនាំអីនៅជាប់គាត់អីចឹងទៅណាស់ តែឲ្យមានការដឹកនាំទ័ពទៅវាយអត់មានទេ ។

ថនៈ ពូនៅខាងម៉ាឡៃហ្នឹងបានយូរទេ?

សុខុមៈ នៅមើលបានប៉ុន្មានដែរ នៅបានដាំត្រឡាច ល្ពៅ បានហូបយូរដែលហ្នឹង ។

ថនៈ នៅដល់គេវាយម៉ាឡៃនៅឆ្នាំ១៩៨៥ខ្ទាំងហ្នឹងពូបាននៅទេ?

សុខុមៈ អត់ទេ ខ្ញុំចេញមកមុនហ្នឹងចេញមកយូរដែលទេ នៅបានតែមួយរយៈដែលទេ បានចេញមកនេះ មកខាងឧត្តរនេះ ។

ថនៈ ចឹងនៅមុនខាងវៀតណាមវាយខ្ទាំងនៅឆ្នាំ១៩៨៥ហ្នឹង?

សុខុមៈ ហ្នឹងហើយ ខ្ញុំមកមុន ។

ថនៈ មកនៅខាងឧត្តរនៅខាងណាវិញពូ?

សុខុមៈ មកនៅខ្នងភ្នំ គេហៅ៨០៨នេះ ។

ថនៈ ៨០៨នៅខាងប-១ហ្នឹងពូ?

សុខុមៈ ហ្នឹងហើយ ។

ជនៈ ៨០៨ចាប់ពីណាដល់ណាពូ?

សុខុមៈ ហ្នឹងម៉ាជំនាវហ្នឹងទាំងអស់ ខាងប-១ហ្នឹង ។

ជនៈ ខាងអូរស្មាច់?

សុខុមៈ អត់មានដល់ហ្នឹងទេ ទៅលិចមានគេផ្សេងៗទៀត មានទុំ មានស្អី ។

ជនៈ កាលហ្នឹងមកតែពូជាមួយតាវឿន ទេឬមានមកទាំងអស់គ្នា ។

សុខុមៈ កាលហ្នឹងមកចំរុះទាំងស្រីទាំងប្រុស ច្រើនអង្គភាព ។

ជនៈ មានអង្គភាពណាខ្លះ?

សុខុមៈ មានអង្គភាពគេច្រើនណាស់ តែពួកខ្ញុំមកប៉ុន្មានរយនាក់ ទាំងគ្រួសារទាំងប្រជាជនអីហ្នឹងមកពីលិចវិញ ពួកតាហុងដឹកនាំ ។

ជនៈ ហ្នឹងគេបំបែកយ៉ាងម៉េចអ៊ឹ នៅខាងហ្នឹងច្រើនគេបំបែកឲ្យមកខាងនេះ?

សុខុមៈ កាលហ្នឹងគេយកជាកម្លាំងឲ្យជួយដឹកជញ្ជូនអីចឹងទៅណាស់ រៀបចំជាមូលដ្ឋានសម្រាប់ការពារកងទ័ពអីចឹងទៅ ។

ជនៈ ចឹងប-១ហ្នឹងបង្កើតឆ្នាំណាពូ ពូមានដឹង៨០៨ហ្នឹង?

សុខុមៈ អត់ដឹងទេ ឃើញគេហៅប-១ៗហ្នឹង ។

ជនៈ ចឹងដល់ពេលពូមកហ្នឹងពីណាគ្រប់គ្រងនៅហ្នឹងពូ ប-១កាលហ្នឹង?

សុខុមៈ ប-១មានតាម៉ន ឈ្មោះ តាម៉ន ចឹងហើយប្រធាន ។

ជនៈ ប-១៨០៨នៅហ្នឹងពីណាអ្នកគ្រប់គ្រងពូ?

សុខុមៈ កងពលគេនោះឈ្មោះ តាសឿន តាសឿន មិនដឹងជាទៅណាបាត់ចូលថៃបាត់ហើយមិនដឹងកាលហ្នឹងមិនដឹងជាឆ្នាំប៉ុន្មានទេ ។

ជនៈ ចឹងគាត់កាន់កងពលលេខប៉ុន្មានតាសឿន ហ្នឹង?

សុខុមៈ កាលហ្នឹងមិនដឹងជាកងពលគេលេខប៉ុន្មានទេ ខ្ញុំមិនបានដឹងលេខគេទេ ។

ជនៈ ចឹងពូមកចូលជាមួយគាត់តែម្ដង?

សុខុមៈ អត់ទេ ខ្ញុំនៅមូលដ្ឋាន ។

ជនៈ ចឹងមូលដ្ឋានហ្នឹងគេបែងចែកយ៉ាងម៉េចទៅ?

សុខុមៈ មូលដ្ឋានរៀបជាអង្គភាពមូលដ្ឋាន ។

ជនៈ តែនៅក្រោមកងពល?

សុខុមៈ អត់ទេ កងពលគេនៅដាច់ដោយឡែក កងពលគេទៅមុខផ្សេង ហើយមូលដ្ឋានគេរៀបខាងក្រោយនេះជាប់ដីថៃនេះ ។

ជន: ចិនដាច់ដោយខ្សែកពីគ្នា?

សុខុម: ដាច់ដោយខ្សែក អត់មានពាក់ព័ន្ធទេ លើកលែងក្រោយមកគេសុំកម្លាំងជួយដឹកជញ្ជូនគ្រាប់អីឲ្យគេទៅចិនទៅណាស់ យើងគ្រាន់តែជញ្ជូនគ្រាប់ទៅ ។

ជន: ចិនកាលហ្នឹងទីសដៅប-១ហ្នឹងមកខាងណាខ្លះពូ មានសកម្មភាព?

សុខុម: ប-១មានស្អីមានតែដឹកជញ្ជូនដូចគ្នាដែលហ្នឹង មានកម្លាំងនារីយុទ្ធជនដូចគ្នា គ្មានធ្វើសកម្មភាពអីទេពូកហ្នឹង ។

ជន: ចង់និយាយថា ខាងមុខព្រួញខាងមុខ?

សុខុម: អត់មានអីទេ ពួកប-១ហ្នឹងដូចខ្ញុំថាចិនក្រុមដឹកជញ្ជូន គេយកកម្លាំងមកដឹកជញ្ជូនដូចខាងខ្ញុំហ្នឹងក៏គេយកកម្លាំងមកដឹកជញ្ជូនដែរ ក្រោយមកគេរើសកម្លាំងដែលមាំទាំចិនទៅ ទៅចូលកងទ័ព នារីហ្នឹងក៏យកទៅចូលអគ្គភាពនារីទាំងអស់ មួយចំនួនទៅខ្ញុំក៏នៅជាប់ខាងក្រោយហ្នឹង ខ្ញុំមានទៅណានៅជាប់តែខាងក្រោយហ្នឹង ។

ជន: នៅខាងដីថៃពូកាលហ្នឹងឬនៅខាងដីខ្មែរទេ?

សុខុម: នៅដំបូងនៅលើដីថៃហ្នឹងតែម្តង នៅជាប់ព្រំដែនថៃ ក្នុងព្រំដែនថៃខ្លះក្នុងដីថៃខ្លះ ។

ជន: មានជំរំមានអីទេពូកាលហ្នឹង?

សុខុម: អត់មានទេ យើងធ្វើផ្ទះនៅធម្មតា លើកផ្លូវធ្វើផ្ទះជាជួរៗលើខ្នងភ្នំចិនទៅណាស់ ចិនហើយគេភូមិតាម៉េត ភូមិតាចក់ចិនទៅ ។

ជន: ភូមិតាម៉េត ភូមិតាចក់ហ្នឹងតាមឈ្មោះអគ្គភាព?

សុខុម: ឈ្មោះភូមិឃុំឈ្មោះអគ្គភាព ។

ជន: ឈ្មោះអគ្គភាព?

សុខុម: ហ្នឹងហើយគេហៅភូមិតាម៉េត ភូមិតាចក់ ក្រោយមកមួយភូមិៗចិន ទៅលិចភូមិយាយថែមចិនទៅណាស់ ។

ជន: ចិនដឹងយ៉ាងម៉េចបានជាហៅប-១?

សុខុម: អាហ្នឹងមិនចិនជាយ៉ាងម៉េចគេដាក់ពីលើមកពួកតាហុងដាក់ អាហ្នឹងខ្ញុំអត់យល់ដែរ ព្រោះអាហ្នឹងនៅក្រោយការគ្រប់គ្រងរបស់តាហុងផ្ទាល់ ។

ជន: ចិនតាហុងហ្នឹងគាត់គ្រប់គ្រងនៅប-១?

សុខុម: គាត់មិនដែលនៅហ្នឹងទេ តែកម្លាំងហ្នឹងពីដើមជាប់ជាមួយតាហុង ជាមន្ទីររបស់តាហុង ជាមន្ទីររបស់តាៗធំចិនណាស់ ។

ជន: ចិនដូចនៅខាងភ្នំពេញគេហៅប-១ នៅក្រសួងការបរទេសអីហ្នឹងពូ?

សុខុមៈ ខ្ញុំមិនដឹងជាយ៉ាងម៉េច ខ្ញុំគ្រាន់តែដឹងថាប-១៦ហ្នឹង ។

ថនៈ កាលហ្នឹងតាហុង គាត់នៅក្នុងក្រសួងការបរទេសជាមួយតាអៀង សារី?

សុខុមៈ បាទ!ដាច់ដោយឡែកពីគ្នាខ្ញុំមិនសូវបានដឹង ។

ថនៈ បាទ!ចឹងពូមានដឹងថា១០០១-១០០២-១០០៣យ៉ាងម៉េចបានជាគេដាក់ឈ្មោះចឹងពូ?

សុខុមៈ អាហ្នឹងជាចំណុចកន្លែងរស់នៅចេះតែដាក់ទៅ ។

ថនៈ ចឹងមានមូលហេតុអីបានជាគេដាក់អាហ្នឹង គេជ្រើសរើស?

សុខុមៈ អាហ្នឹងវាមិនខុសអីពីគេដាក់តំបន់ទេ វាដូចតែគ្នាហ្នឹងដូចនៅ១០០៣ហ្នឹង ទេមិនដឹងជាយ៉ាងម៉េច ឃើញគេដាក់តែចឹង អាខ្លះដាក់តាមដូចមានអីត្រង់ហ្នឹងដាក់តាមហ្នឹងទៅ ។

ថនៈ ចឹងខាងណាកើតមុនគេពូ ដូចជា១០០១-១០០២-១០០៣ប-១ចឹងអូរគ្រាវចឹង?

សុខុមៈ អូរគ្រាវក្រោយទេ វៀតណាមវាយដាច់តាមព្រំដែនអស់ហើយបានកើតជាជំរំ ។

ថនៈ ចឹងក្រោយមកគេដាក់តៗគ្នាខាងណាមុនពូ?

សុខុមៈ ដូចតែគ្នាតាមមើលព្រំដែនដូចតែគ្នា តាមមើលស្រុករគ្នា ។

ថនៈ មានខាងណាកើតមុនក្រោយ?

សុខុមៈ មិនដឹងជាយ៉ាងម៉េច វាដូចជាមិនមុនក្រោយទេ ឡើងមកកនទ័ពនៅតាមបណ្ដោយព្រំដែនរហូតណាស់នៅ១០០១ក៏គេមានកនទ័ព មានគ្រួសារកនទ័ពមានប្រជាជនចឹងទៅ១០០២មានដូចគ្នាចឹងទៅ១០០៣ក៏ដូចគ្នា៨០៨ក៏ដូចគ្នា ។

វណ្ណៈ ចឹងកាលហ្នឹង១០០១ពីណាគ្រប់គ្រង?

សុខុមៈ ១០០១មានតាសុន សេន ហ្នឹងហើយ ខ្ញុំមិនសូវយល់ទេ មួយកំណាត់ខាងកើតហ្នឹង ។

វណ្ណៈ ចឹង១០០២?

សុខុមៈ អត់ដឹង ។

វណ្ណៈ ចឹង១០០៣?

សុខុមៈ ១០០៣តាម៉ុក ហ្នឹង តែនិយាយរួមទៅតាម៉ុក គាត់គ្រប់គ្រងទាំងអស់តាមព្រំដែនហ្នឹង តែគាត់ឈរជាប់នៅ១០០៣ ។

វណ្ណៈ ចឹងតាម៉ុក មានដែលជួបគាត់និយាយលេងជាមួយគាត់ផ្ទាល់ទេ?

សុខុមៈ ជួប តែមិនបាននិយាយលេងទេ តែបានជួប ។

វណ្ណៈ ចឹងក្រោយមកទៀតពូមកខាងភ្នំដងរែកជាមួយតាម៉ុកដែលឬមួយអត់ទេ?

សុខុមៈ ខ្ញុំនៅខាង៨០៨ដូចខ្ញុំនិយាយមិញហ្នឹង ។

វណ្ណៈ ចឹងនៅ៨០៨ពីណាគេគ្រប់គ្រង?

សុខុមៈ ៨០៨កាលហ្នឹងនៅតាមភូមិរៀងៗខ្លួន កាលហ្នឹងក្ដាប់រួមពីណាទេ ដូចជា តាចៀម ជនជាតិតាហ្នឹង ។

វណ្ណៈ គាត់ឥឡូវនៅម៉ាឡៃ?

សុខុមៈ ហ្នឹងហើយ គាត់ចេញពីហ្នឹងទៅមិនដឹងជាគាត់ទៅនៅណា ។

វណ្ណៈ ចឹងនៅ៨០៨ដាច់ចេញពីតាម៉ុកទេ?

សុខុមៈ ទេ តាម៉ុក គាត់គ្រប់គ្រងទាំងអស់ តែគ្រាន់តែគាត់មិននៅជាប់ហ្នឹង ។

វណ្ណៈ ចឹងពូយល់ថា តាម៉ុក គាត់ជាមនុស្សយ៉ាងម៉េចដែរ?

សុខុមៈ មិនដឹងជាយ៉ាងម៉េច ព្រោះយើងមិនសូវបានគៀកបានជាប់ ។

វណ្ណៈ ចឹងផ្លូវចុះមកពីភ្នំដងរែកពូគិតថា ឆ្នាំណាដែលតាម៉ុក ឈូសឆាយនាំប្រជាជនមកនៅតាមភូមិបង្កើតចេញជាភូមិជាអីចឹង?

សុខុមៈ ដូចជាឆ្នាំ១៩៨៩-៩០ហ្នឹង ។

វណ្ណៈ ចឹងចាប់ផ្ដើមឈូសផ្លូវនាំប្រជាជនចុះមករស់នៅតាមភូមិ?

សុខុមៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងកាលយើងធ្វើសង្គ្រាមជាមួយវៀតណាមកាលហ្នឹង មុនវៀតណាមដកទៅកាលហ្នឹងសង្គ្រាមបានគ្រាប់រំសេវបានមកពីខាងណា?

សុខុមៈ កាលពីដើមវាមានជំនួយមកពីចិនហ្នឹងហើយ ។

វណ្ណៈ ចឹងមានជំនួយចិន?

សុខុមៈ បាទ!កាលពីដំបូងមានចិនហ្នឹងហើយ ។

វណ្ណៈ ចឹងកាលវៀតណាមដកទៅវិញពូមានបានដឹងទេ?

សុខុមៈ ឆ្នាំប៉ុន្មានទេ ។

វណ្ណៈ ចឹងនៅពេលវៀតណាមដកទៅវិញនៅសល់តែខ្មែរវាយគ្នាចឹង តើមានវាយគ្នាខ្លាំងដែរទេ?

សុខុមៈ អស់ហើយ ។

វណ្ណៈ ចឹងបានជាតាម៉ុក ហ៊ានធ្វើផ្លូវចុះមកពីលើភ្នំចុះមកនៅតាមឃុំអី?

សុខុមៈ អត់មានអីទេ ។

វណ្ណៈ ចឹងកាលនៅកម្លាំងវៀតណាមវាយខ្លាំង?

សុខុមៈ កាលមានវៀតណាមនៅលើភ្នំ កាលហ្នឹងកម្ពុជាស្បៀយគ្រាប់ស្បៀយអីហើយ ឆ្នាំប៉ុន្មានទេ កាលហ្នឹងវៀតណាមដកនោះ ដូចជាឆ្នាំ១៩៩០-៩១ហ្នឹងឯង ។

វណ្ណៈ តាមឯកសារឆ្នាំ១៩៨៩?

សុខុមៈ ហ្នឹងហើយឆ្នាំ១៩៨៩-៩០ហ្នឹង ។

ផនៈ ចឹងពូមានទៅម៉ាជួរព្រះវិហារទេ?

សុខុមៈ អត់ទេ ជំនាន់សង្គ្រាមខ្ញុំមិនដែលទៅណាផង ។

វណ្ណៈ ចឹងក្រោយឆ្នាំ១៩៧៩ពូនៅក្រោយជាមួយប្រជាជន?

សុខុមៈ ហ្នឹងហើយ ។

វណ្ណៈ ចឹងកាលហ្នឹងប្រជាជនទទួលរបបអាហារហ្នឹងពីណាជាបែងចែកឲ្យ?

សុខុមៈ កាលហ្នឹងខាងជំនួយ ។

វណ្ណៈ ជំនួយតែតាម៉ុក គាត់អ្នកគ្រប់គ្រង?

សុខុមៈ បាទ!ឧទាហរណ៍ប្រក៨០៨ហ្នឹងគេដឹកយកមកដល់តែម្តង ។

វណ្ណៈ ចឹងប្រជាជនអត់មានខ្វះខាតទេ?

សុខុមៈ អត់ទេ ខ្វះខាតពេលយើងកំពង់រត់ដំបូង អាហ្នឹងរកអ្នកជំនួយឧបត្ថម្ភមិនទាន់ឃើញអាហ្នឹងខ្វះខាត តែក្រោយពីមានមូលដ្ឋានត្រឹមត្រូវមកអង្ករលែងខ្វះហើយ ចោទតែរឿងម្ហូបអាហារទេ កាលហ្នឹង យើងរកហូបខ្លួនឯង តែអង្ករហូបដល់សល់ចោលទៀត ។

វណ្ណៈ ចឹងកាលពូមកដល់ព្រំដែនដំបូងហើយមានភាពខុសប្លែកគ្នាយ៉ាងម៉េចខ្លះដែលរឿងព្រៃឈើ?

សុខុមៈ កាលដំបូងសុទ្ធតែព្រៃ ។

វណ្ណៈ ចឹងកាលហ្នឹងសត្វក៏សម្បូរដែរ?

សុខុមៈ សត្វពេញហើយ ។

វណ្ណៈ ឥឡូវយើងលែងមានព្រៃច្រើនទៀតហើយ?

សុខុមៈ ឥឡូវអស់ហើយ ទៅជាចម្ការទៅជាស្រែ កាលពីដើមផ្តុំហ្នឹងសុទ្ធតែមីន ។

វណ្ណៈ ចឹងមានមីន?

សុខុមៈ បាទ ។

វណ្ណៈ ចឹងយើងមានគ្រោះថ្នាក់ច្រើនដែលដោយសារមីន?

សុខុមៈ កាលខ្ញុំមកនៅនេះមានស្លាប់អស់ប៉ុន្មាននាក់ដែរ កាលមកដល់ដំបូង ។

វណ្ណៈ ចឹងកាលពូចេញពី៨០៨មកនៅភូមិនេះតែម្តងឬក៏ពូទៅណាសិន?

សុខុមៈ កាលហ្នឹងរត់ពីវៀតណាមវាយកាលឆ្នាំ១៩៨៥ រត់ទៅនៅក្នុងទឹកដីថៃបណ្តោយតាមនេះចឹងទៅ ទាល់តែឆ្នាំ១៩៨៩-៩០បានចុះមក ។

វណ្ណៈ ចឹងឆ្នាំណាដែលពូបានមកនៅហ្នឹងពិតប្រាកដ?

សុខុមៈ មកនៅនេះឆ្នាំ១៩៩០ ខ្ញុំស្រួលណាស់មិនសូវបានហត់នឿយទៅធ្វើអីទេ អត់មានទៅប្រយុទ្ធទៅច្បាំងអីណាទេ ។

វណ្ណៈ ចឹងកាលអ៊ុនគាត់ចូលមកពូមានបានបោះឆ្នោតអីទេ?

សុខុមៈ អត់ទេ បោះពេលនេះហើយ លើកមុនអត់ទេ ។

វណ្ណៈ ចឹងមិនបានបោះទេឆ្នាំ១៩៩៣?

សុខុមៈ អត់ទេ ។

វណ្ណៈ ចឹងកាលហ្នឹងខាងអ៊ុនគាត់ចូលអត់បានទេនៅម្តុំហ្នឹង?

សុខុមៈ អត់ទេ ។

វណ្ណៈ ក្រោយពីកម្លាំងខ្មែរក្រហមប្រកាសមិនចូលរួមកាលបោះឆ្នោតអ៊ុនកាត់ក៏ចូលមិនបានដែរ?

សុខុមៈ អត់ទេ ។

វណ្ណៈ តែកាលពីដំបូងមានកម្លាំងអ៊ុនគាត់ចូលមកត្រឹមអន្លង់វែងមានទេ?

សុខុមៈ ដូចជាអត់មានទេ ។

វណ្ណៈ ចឹងក្រោយមកទៀតនៅតំបន់ខាងតាម៉ុក ហ្នឹងក្រោយមកទៀតមានចាប់តាប៉ុល ពត កាត់ទោសអីហ្នឹងមកពីរឿងអីដែរ?

សុខុមៈ គ្មានអីពីរឿងដណ្តើមអំណាចទេ ។

វណ្ណៈ ចឹងរឿងដណ្តើមអំណាច?

សុខុមៈ ហ្នឹងហើយ នៅក្រោមៗដណ្តើមអំណាចគ្នា ។

វណ្ណៈ ចឹងកាលតាសុន សេន ស្លាប់ពូអាចដឹងទេ មានបានខ្លះទេហេតុការណ៍ហ្នឹង គេសម្លាប់គាត់ព្រមទាំងគ្រួសារ?

សុខុមៈ រឿងគំនុំដណ្តើមអំណាចគ្នា ។

វណ្ណៈ ដល់ក្រោយមកគេចោទតា០៥-០៦ទៅបង្រ្កាបទៅសម្លាប់ក្រុមគ្រួសារហ្នឹងតើទៅសម្លាប់មែនឬមិនមែនទេ ដល់ក្រោយមកតាម៉ុក ចាប់តា០៥តា០៦ទៅសម្លាប់ចោលក្រោយទៀតហ្នឹងយកទៅសម្លាប់វិញ?

សុខុមៈ តា០៥មែនហ្នឹង ។

វណ្ណៈ ចឹងកម្លាំងគាត់មិនមែនគាត់ទៅទេ?

សុខុមៈ គាត់ទៅដែលអីមិនដឹងកាលហ្នឹង ខ្ញុំមិនសូវបានដឹងដែរ ។

វណ្ណៈ ចឹងក្រោយពីសម្លាប់តាសុន សេន ហើយរឿងរ៉ាវនៅក្នុងអន្លង់វែងហ្នឹងចេះតែបែកធ្លាយរៀលដាបន្តទៀត?

សុខុមៈ	បែកផ្ទុះត្រឹមហ្នឹងបណ្ដោយ ។

វណ្ណៈ:	ចឹងពេលហ្នឹងលែងទុកចិត្តគ្នាមានអ្នកលបលួចទៅខាងរដ្ឋាភិបាលដើម្បីរកច្រកចេញអីចឹង ចឹងសូមរៀបរាប់ត្រួសៗពីបញ្ហាហ្នឹង ហេតុអីបានឈានដល់មានសមាហរណ៍កម្មអីចឹង?

សុខុមៈ	ចុះបើផ្ទៃក្នុងវាលែងត្រូវគ្នាហើយ វាមែនទែនកាលហ្នឹងវាបែងចែក ឧទាហរណ៍ខាង ប៉ុល ពត នោះផ្សេងចឹងទៅខាងតាម៉ុក ផ្សេងចឹងទៅ មានមួយប៉ែកខាងកើតចឹងទៅគាំទ្រខាង ប៉ុល ពត ចឹងទៅ ប៉ែកខាងលិចគាំទ្រតាម៉ុកចឹងទៅ ដល់ចឹងកម្លាំងគាំទ្រខាងតាម៉ុក មានច្រើនជាង កាលហ្នឹង ។

វណ្ណៈ:	ខាងអន្លង់វែង?

សុខុមៈ	ខាងអន្លង់វែង ។

វណ្ណៈ:	ចឹងខាងត្រពាំងប្រាសាទគាំទ្រខាង ប៉ុល ពត?

សុខុមៈ	ហ្នឹងហើយ ។

វណ្ណៈ:	ចឹងមានយ៉ាងម៉េចទៀតពូ?

សុខុមៈ	ដល់ហើយតាគាត់បេះតែរៀបកម្លាំងឡើងធ្វើសកម្មភាពចឹងទៅណាស់ តែឡើងទៅហ្នឹងគ្មានវាយតប់អី ព្រោះថាខាងនោះក៏រៀបចំកម្លាំងវាយខាងនេះ ខាងនេះក៏រៀបកម្លាំងឡើងទៅតែមិនបានវាយទេ ពេលជួបគ្នាទៅសុទ្ធតែគ្នាឯងចាប់ដៃគ្នាទៅ បេះតែផ្សះផ្សារគ្នាចប់ចឹងទៅ ក្រោយមកតាៗហ្នឹងចុះមកក្រោយអស់មក តាៗចុះមកចប់បណ្ដោយហ្នឹងវាអត់មានរឿងអីវែងឆ្ងាយទេ ។

ជនៈ	ចឹងកាលហ្នឹង នួន ជា ខៀវ សំផន គាត់នៅហ្នឹងដែរ?

សុខុមៈ	តាៗ នៅហ្នឹងទាំងអស់ ។

វណ្ណៈ:	នៅខាងអន្លង់វែងហ្នឹង?

សុខុមៈ	បាទ ។

វណ្ណៈ:	ចឹងក្រោយមកទៀតបានគាត់ទៅខាងប៉ៃលិនវិញ?

សុខុមៈ	អត់ទេ គាត់មកពីលិចវិញតើ ។

វណ្ណៈ:	គាត់មកពីលិចវិញ តែពេលសមាហរណ៍កម្មអីហើយពួកគាត់ត្រឡប់ទៅខាងប៉ៃលិនវិញ?

សុខុមៈ	ទេ ពេលសមាហរណ៍កម្មហើយ កាលហ្នឹងពួកគាត់ទៅណាមិនបានដឹងទេ ទៅលិចតាមមើល ។

វណ្ណៈ:	ចឹងកាលមិនទាន់សមាហរណ៍កម្មពួកគាត់ទៅនៅលើភ្នំដងរែកទាំងអស់គ្នា?

សុខុមៈ	បាទ ។

វណ្ណៈ៖ ចឹងកម្លាំងដឹកនាំចូលសមាហរណ៍កម្មហ្នឹង ទៅចូលជាមួយរដ្ឋាភិបាលពូដឹងទេ ពីណាកាលហ្នឹងអ្នកដឹកនាំកម្លាំងទៅ?

សុខុមៈ ខាងលិចខាងអន្លង់វែងមាន មានតាយឹម ដាន់ណា មាន យឹម ពឹម យឹម សាន អីហ្នឹង។

វណ្ណៈ៖ ចឹងខាងត្រពាំងប្រាសាទ?

សុខុមៈ ខាងត្រពាំងប្រាសាទ មាន ជុំ ជាតិ តែ ជុំ ជាតិ គាត់ទៅមុន ទៅមុនក្រុមខាងលិច។

វណ្ណៈ៖ ចឹងពេលសមាហរណ៍កម្មពិតប្រាកដយើងមានសន្តិភាព លែងមានសង្គ្រាមគ្នាតទៀតនៅឆ្នាំណាពូមានចាំទេ?

សុខុមៈ នៅឆ្នាំ១៩៩៨។

វណ្ណៈ៖ ចឹង៩៨-៩៩ហ្នឹង?

សុខុមៈ បាទ។

វណ្ណៈ៖ ចឹងពេលហ្នឹងយើងលែងរត់លូនទៀតហើយ?

សុខុមៈ បាទ។

វណ្ណៈ៖ ចឹងយើងមានភូមិ?

សុខុមៈ យើងនៅភូមិដដែលតែគេប្រកាសរៀបចំកងទ័ព រៀបចំមូលដ្ឋានមានភូមិមានឃុំអីតាមរដ្ឋាភិបាលរៀបចំណាស់ មានចាត់តាំងកងពល២៣-២៨កងពលធំ ខាងកើត២៨ខាងលិច២៣។

វណ្ណៈ៖ ចឹងបានបង្កើតភូមិដល់សព្វថ្ងៃហ្នឹងទៅ?

សុខុមៈ បាទ! ហើយភូមិហ្នឹងវាមានក្រិត្យតាំងពីហ្នឹងមក។

វណ្ណៈ៖ ចឹងមានកម្លាំងមួយចំនួនដូចជាពូបានចូលទៅខាងរដ្ឋាភិបាលចឹងទៅ ពូមានទទួលតួនាទីអីដែលសព្វថ្ងៃ?

សុខុមៈ ខ្ញុំជាមេបញ្ជាការរងកងពលតូច កាលហ្នឹងបើនិយាយជាវរសេនាធំ តែមេរង។

វណ្ណៈ៖ ចឹងមេពីណាវិញ?

សុខុមៈ កាលហ្នឹង សយ សឿន។

វណ្ណៈ៖ ចឹងរាល់ថ្ងៃពូនៅមានតួនាទីដដែលតើ?

សុខុមៈ សេនាធិការរង។

វណ្ណៈ៖ ចឹងពូប្រចាំនៅខាងទីសព្រះវិហារនេះ?

សុខុមៈ បាទ! ខ្ញុំអត់ស្រួលខ្លួនបានមកផ្ទះ។

វណ្ណៈ៖ ចឹងពូគិតថា កាលពីសង្គ្រាមមកដល់សម័យឥឡូវបើធ្វើការប្រៀបធៀបគ្នាទៅកាលសម័យតស៊ូនិងសម័យឥឡូវមួយណាស្រួលជាង?

សុខុមៈ សម័យឥឡូវស្រួលជាង យើងចង់ទៅណាក៏បាន កាលមុនការហូបចុកវាមិនមានអីទំនើបដូចជាសព្វថ្ងៃ ឥឡូវយើងហូបបរបូរយើងចង់ហូបអីក៏បានឲ្យតែយើងមានលុយ យើងចង់បានអីក៏បាន ហើយសិទ្ធសេរីភាពយើងក៏បានពេញទី យើងកុំឲ្យតែដើរជាន់គេ ។

វណ្ណៈ ចឹងពូរាល់ថ្ងៃហ្នឹងពូកាន់សាសនាអីដែរ.

សុខុមៈ កាន់សាសនាព្រះពុទ្ធ ។

វណ្ណៈ យើងឥឡូវមានសាសនាបរបូរដែលយើងចង់កាន់សាសនាណាក៏បាន?

សុខុមៈ បាទ ។

វណ្ណៈ ពូយល់ថា សាសនាព្រះពុទ្ធយ៉ាងម៉េចដែរ?

សុខុមៈ និយាយទៅយើងចេះតែទម្លាប់មកទៅហើយ ។

វណ្ណៈ ចឹងយើងគោរពសាសនាព្រះពុទ្ធហ្នឹងយើងអាចមានផលប្រយោជន៍អីដែរ ឲ្យយើងប្រព្រឹត្តិអំពើល្អឬមួយយ៉ាងម៉េចដែរ?

សុខុមៈ ពិបាកដែរ ស៊ីសង់លើបុគ្គលទេ យើងកាន់ព្រះពុទ្ធសាសនាចេះតែល្អហើយ តែមានអ្នកខ្លះមិនបានធ្វើតាមសាសនាហ្នឹង ។

វណ្ណៈ ចឹងកាលជំនាន់បីឆ្នាំអត់មានសាសនាទេ អត់មានវត្តអីទេ?

សុខុមៈ បាទ ។

វណ្ណៈ ចឹងរាល់ថ្ងៃហ្នឹងពូរស់នៅជិតខាងហ្នឹងមានទំនាក់ទំនងគ្នាយ៉ាងម៉េចដែរ?

សុខុមៈ អត់មានអីទេធម្មតា ដូចជាបងដូចជាប្អូនធម្មតាអត់មានអីផង ជួយគ្នាធម្មតា ការរកស៊ីលុយកាក់ជារឿងម្យ៉ាង បើម្យ៉ាងមានអីផ្សេងៗជួយគ្នា វាធម្មតាទេ ។

វណ្ណៈ ចឹងបញ្ហាដីធ្លីមកដល់សព្វថ្ងៃហ្នឹង តើមានប្រជាជនមានផលប៉ះពាល់ដែលឬខាងរដ្ឋាភិបាលយើងអាចជួយដោះស្រាយបានខ្លះដែរឬមួយយ៉ាងម៉េច មានទេនៅក្នុងស្រុកភូមិហ្នឹង?

សុខុមៈ អត់មានអីទេ ។

វណ្ណៈ ចឹងអត់មានប៉ះពាល់ដីក្រុមហ៊ុនទេ?

សុខុមៈ អត់ទេ និយាយរួមកន្លែងនេះអត់មានទេ មានគេផ្សេងៗចេះតែព្រៃតែភូមិនេះទទេតែម្ដង ។

វណ្ណៈ ចឹងបើសិនជាមានរឿងអីកើតឡើងពូអាចពឹងពាក់ទៅលើផ្នែកច្បាប់យើងសព្វថ្ងៃបានទេ?

សុខុមៈ អាហ្នឹងមានតែតាមច្បាប់ហ្នឹងហើយ យើងរស់នៅក្រោមច្បាប់របស់រដ្ឋាភិបាល ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនហើយដែលបានផ្ដល់បទសម្ភាសឲ្យខាងខ្ញុំទុកជាប្រវត្តសាស្ត្រ ។

សុខុមៈ បាទ ។

**ចប់**